ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ការិយាល័យអ្នកនាំពាក្យ

# សេចក្តីប្រកាសបដិសេធ
## ចំពោះការចោទប្រកាន់ មួលបង្កាច់ របស់សារព័ត៌មាន ឌឹខេមបូឌា ដេលី ខ្មែរ មកលើ ឯកឧត្តម ម៉េង ហុង អគ្គនាយកបេឡាជាតិសន្តិសុខសង្គម

ការិយាល័យអ្នកនាំពាក្យ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមបដិសេធទាំងស្រុងចំពោះការផ្សាយព័ត៌មានមិនពិតរបស់សារព័ត៌មាន ឌឹខេមបូឌា ដេលី ខ្មែរ (The Cambodia Daily Khmer) នាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ ដែលបានចោទប្រកាន់ មួលបង្កាច់មកលើ ឯកឧត្តម ម៉េង ហុង អគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពាក់ព័ន្ធការទទួលសំណូកពីមណ្ឌលសុខភាព និងគ្លីនិកឯកជន។

ការិយាល័យអ្នកនាំពាក្យ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមបញ្ជាក់ថានីតិវិធីនៃការចុះកិច្ចព្រមព្រៀងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលឯកជន គឺប្រើយន្តការរួម ដោយមានក្រុមប្រឹក្សាវេជ្ជសាស្ត្រ និងនិយ័តករសន្តិសុខសង្គម ចូលរួមកំណត់កម្រិតផ្តល់សេវា និងឯកភាពលើការស្នើសុំចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលឯកជន។ បេឡាជាតិសន្តិសុខសង្គមកំពុងរៀបចំកែសម្រួលនីតិវិធីនៃការចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលឯកជនឡើងវិញ ដើម្បីកំណត់សុពលភាពនៃការអនុវត្តកិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល ស្របតាមគោលការណ៍ណែនាំស្តីពីយន្តការ និងនីតិវិធីនៃការពិនិត្យឡើងវិញលើការចុះកិច្ចព្រមព្រៀងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលឯកជនរបស់និយ័តករសន្តិសុខសង្គម។

ការិយាល័យអ្នកនាំពាក្យ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កត់សម្គាល់ឃើញថាការផ្សាយព័ត៌មានមិនពិតនេះ មានចេតនាមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ ឯកឧត្តម ម៉េង ហុង ដោយគ្មានក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន គ្មានការទទួលខុសត្រូវ និងធ្វើឱ្យមានការយល់ច្រឡំពីសាធារណជន។ សារព័ត៌មាន ឌឹខេមបូឌា ដេលី ខ្មែរ (The Cambodia Daily Khmer) ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានឱ្យបានត្រឹមត្រូវ និងកែតម្រូវការផ្សាយរបស់ខ្លួនជាបន្ទាន់។

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាបជាព័ត៌មាន និងកុំចែកចាយបន្តចំពោះអត្ថបទដែលគ្មានការពិត និងគ្មានវិជ្ជាជីវៈខាងលើនេះ។

ថ្ងៃសុក្រ ១១រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤